**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# សារថ្វាយព្រះពរ

**សូមក្រាបបង្គំទូលថ្វាយ**
**ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី**
**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ !**

ក្នុងឱកាសដ៏នក្ខត្តឫក្សនៃទិវា **បុណ្យចូលឆ្នាំសកល ឆ្នាំ ២០១៦** នេះ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំង នាយទាហាន នាយទាហានរង និងពលទាហាន នៃ កងយោធពលខេមរភូមិន្ទទាំងមូល សូមព្រះករុណាថ្លៃវិសេស ជាអង្គម្ចាស់ជីវិតតម្កល់លើត្បូង ទ្រង់ព្រះមេត្តា ប្រោសព្រះបរមរាជានុញ្ញាតឲ្យទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នាសូមសម្តែងនូវកតញ្ញូកតវេទិតាធមិដ៏ខ្ពង់ខ្ពស់បំផុត ថ្វាយចំពោះ ព្រះមហាករុណាទិគុណ នៃព្រះករុណាថ្លៃវិសេសដែលបាន និងកំពុងបំពេញព្រះរាជកិច្ចដ៏មមាញឹក ក្នុងព្រះរាជបេសកកម្មក្នុង និងក្រៅប្រទេសដ៏ថ្លៃថ្លារបស់ព្រះអង្គ ក្នុងការបន្តធ្វើឲ្យមាននិរន្តរភាព ស្ថិរភាព នយោបាយ ដើម្បីឧត្តមប្រយោជន៍ជាតិមាតុភូមិ និងប្រជាពលរដ្ឋ នៃព្រះរាជាណាចក្រកម្ពុជា នាំមកនូវ សុខសន្តិភាពនិងអភិវឌ្ឍន៍ប្រទេសជាតិឲ្យសម្បូររុងរឿងនិងបន្តលើកកម្ពស់កិត្យានុភាព នៃព្រះរាជាណាចក្រ កម្ពុជាឲ្យកាន់តែខ្ពស់ត្រដែតត្រចះត្រចង់លើឆាកអន្តរជាតិ។

ក្នុងឆ្នាំ២០១៥ក៏ដូចជាឆ្នាំមុនៗដែរ នៅពេលដែលប្រជាពលរដ្ឋជួបប្រទះរងគ្រោះដោយសារគ្រោះ ធម្មជាតិ ក៏ដូចជាប្រជាពលរដ្ឋទីទ័លក្រនៅតាមតំបន់ជនបទដាច់ស្រយាលជួបការលំបាកខ្វះខាត ព្រះអង្គតែង តែយាងចុះសួរសុខទុក្ខ និងចែកព្រះរាជអំណោយ ដើម្បីជួយសម្រួលនូវទុក្ខលំបាករបស់ប្រជាពលរដ្ឋ។ កត្តាទាំងនេះ បានធ្វើឲ្យទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា ក៏ដូចជាប្រជារាស្ត្រខ្មែរទូទាំងប្រទេស មានមោទនភាព ក្រៃលែង និងស្មោះស្ម័គ្រដង្ហែតាមព្រះរាជតម្រិះរបស់ព្រះអង្គជារៀងរហូត។

ក្នុងទិវាដ៏ថ្លៃថ្លានេះ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមលំឱនកាយវាចាចិត្តបួងសួងចំពោះគុណបុណ្យ ព្រះរតនត្រ័យ ព្រមទាំងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតារក្សាព្រះមហាស្វេតឆ្ឆត្រ ព្រមទាំងព្រះរាជ តេជបារមី នៃព្រះអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ ពិសេសព្រះរាជវិញ្ញាណក្ខន្ធ ព្រះបរម រតនកោដ្ឋ សូមទ្រង់ព្រះមេត្តាប្រោស ព្រះរាជទានប្រសិទ្ធពរជ័យបវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរ ថ្វាយចំពោះព្រះករុណា ព្រះបាទសម្តេច **ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណា

ចក្រកម្ពុជាជាទីសក្ការៈ សូមទ្រង់ប្រកបដោយព្រះរាជសុខភាពល្អបរិបូរណ៍ព្រះជន្មាយុយឺនយូរ ព្រះបញ្ញាញាណវាងវៃ ដើម្បីទ្រង់គង់ប្រថាប់នៅជាម្លប់ដ៏ត្រជាក់ត្រជុំ និងផ្តល់នូវសេចក្តីសុខក្សេមក្សាន្តចម្រើនរុងរឿងដល់ប្រជារាស្ត្ររបស់ព្រះអង្គអស់កាលជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** ជាទីសក្ការៈទ្រង់ព្រះមេត្តាប្រោសទទួលនូវគោរវភក្តីភាពដ៏ខ្ពង់ខ្ពស់បំផុត អំពីទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា។

សេចក្តីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស។

សូមក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ ធ្នូ ឆ្នាំ ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

នាយឧត្តមសេនីយ៍ **ទៀ បាញ់**